## ១០. កម្មវិធីការស្ថាប័ន និងការត្រួតពិនិត្យបរិស្ថាន

១៧៣. យោងតាមវិធានការគ្រប់គ្រងដូចមាននៅក្នុងរបាយការណ៍វាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន សំរាប់គំរោងស្រាវជ្រាវនឹងធ្វើអាជីវកម្មរ៉ែ ម្ចាស់គំរោងជាអ្នកទទួលខុសត្រូវ សំខាន់ក្នុងការគ្រប់គ្រងបរិស្ថានរបស់គំរោងនេះ ចំណែកឯក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអាជ្ញាធរខេត្ត ជាអ្នកពិនិត្យការអនុវត្តនីរបស់ម្ចាស់គំរោង ។

១៧៤. ម្ចាស់គំរោងនឹងរៀបចំផែនការគ្រប់គ្រងបរិស្ថានសំរាប់ដំណើរប្រតិបត្តិការស្រាវជ្រាវនឹងធ្វើអាជីវកម្មរ៉ែ ដោយការផ្តល់នូវការអនុវត្តន៏ជាលំអិត និងវិធានការកាត់បន្ថយផលប៉ះពាល់ជាក់ស្តែងលើទីវាល (ពោលគឺកម្មវិធីតាមដានត្រួតពិនិត្យវាយតម្លៃជាប្រចាំនូវរាល់សកម្មភាពអាជីវកម្ម ជាពិសេសចំពោះការលាងរ៉ែឆៅ ការគ្រប់គ្រង សំណល់រាវ និងការរក្សានិងការពារកាកសំណល់រ៉ែ (សំណល់រឹង) ។ កម្មវិធីតាមដានត្រួតពិនិត្យវាយតម្លៃត្រូវធ្វើទៅតាមវិធានការកាត់បន្ថយផលប៉ះពាល់ដូចមានបង្ហាញនៅក្នុងរបាយការណ៍ EIA ដែលមានសង្ខេបនៅក្នុងតារាង ១០-១។ ម្ចាស់ក្រុមហ៊ុនត្រូវជ្រើសរើសអ្នកសម្របសម្រួលបរិស្ថាន២នាក់ ដែលត្រូវប្រចាំការទីនោះ (Local Environmental Coordinator) ដែលមានសមត្ថភាពសមស្របសម្រាប់ការងារនេះ យកមកធ្វើការបណ្តុះបណ្តាលសម្រាប់ការពិនិត្យ តាមដានដំណើរការរបស់ប្រព័ន្ធធ្វើអោយទឹករង (Sedimentation System) និង ប្រព័ន្ធរក្សានិងការពារកាកសំណល់ (Tailing Impoundment System): (១) ទិន្នន័យប្រតិបត្តិការ ជាប្រចាំនៃដំណើរការរបស់ប្រព័ន្ធទាំងមូល (២) ទិន្នន័យដែលអាចប្រើដើម្បីចងក្រងជាឯកសារអំពីដំណើប្រតិបត្តិការរបស់ប្រព័ន្ធ (៣) ទិន្នន័យអាចប្រើដើម្បីអនុវត្តន៏នូវកម្មវិធីថ្មីទៀត និង (៤) ទិន្នន័យដែលត្រូវការ សំរាប់បំពេញរបាយការណ៍ជាផ្លូវច្បាប់ ។ ដើម្បីសំរេចបាននូវបំណងនៃកម្មវិធីយកសំណាកទិន្នន័យដែលប្រមូលបាន ចាំបាច់ត្រូវមានលក្ខណៈ (ក) ជាតំណាង (Representative): ទិន្នន័យចាំបាច់ត្រូវបង្ហាញអំពីលក្ខណៈរបស់ សំណល់រាវឬកន្លែងដែលត្រូវបានយកសំណាក (ខ) អាចប្រើឡើងវិញបាន (Reproducible) ទិន្នន័យដែល ទទួលបានត្រូវមានលក្ខណៈអាចប្រើប្រាស់ឡើងវិញបានដោយអ្នកផ្សេងតាមរយៈការយកសំណាកដដែលនោះ និងរបៀបនៃការធ្វើវិភាគ (គ) ដែលអាចការពារបានការចងក្រងជាឯកសារចាំបាច់ត្រូវមានលក្ខណៈដែលអាចបញ្ជាក់ពីភាពត្រឹមត្រូវនៃនីតិវិធី (ឬដំណើរការ) នៃការយកសំណាក(ឃ) មានសារៈប្រយោជន៏ (Useful): ទិន្នន័យអាចប្រើប្រាស់ដើម្បីឆ្លើយតបទៅនឹងកម្មវត្ថុនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើដំណើរ ការរបស់ប្រព័ន្ធបាន និង (៥) ដឹកនាំការត្រួតពិនិត្យផ្សេងៗទៀតដូចមានពណ៌នានៅក្នុង EMP ។

## តារាង១០-១: សង្ខេបវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| ដំណាក់កាលស្រាវជ្រាវរុករករ៉ែ - | | | | |
| ការធ្វើផែនការ | បទដ្ឋានសម្រាប់ការធ្វើផែនការស្រាវជ្រាវ នឹងធ្វើអាជីវកម្មរ៉ែ | • កំណត់អំពីចង្វាក់ និងរបៀបនៃប្រតិបត្តិការចំរ៉ាញ់ (ទាញ) យករ៉ែ និងវិធីសាស្រ្តក្នុងការបិទរណ្តៅរ៉ែ និងការជួសជុលបរិស្ថានឡើងវិញ។ នៅក្នុងការរៀបចំផែនការចាំបាច់ត្រូវពិចារណាទៅលើបញ្ហាមួយចំនួនដូចខាងក្រោម:<br>(១) ការឈួសបកដីស្រទាប់លើ ការរក្សានិងគ្រប់គ្រងអាចម៍ដីនេះអោយបានត្រឹមត្រូវសម្រាប់ប្រើនៅពេលបិទរណ្តៅរ៉ែ ។<br>(២) រៀបចំទីស្នាក់ការ ផ្ទះសម្រាប់បុគ្គលិកកម្មករស្នាក់នៅ រោងជាង សួនច្បារ និងទីលានកីឡា។<br>(៣) កំណត់ទីតាំងសម្រាប់រក្សានិងការពារកាកសំណល់ (អាចម៍) រ៉ែ ជាពិសេសប្រសិនបើកាកសំណល់ទាំងនោះមានសារធាតុ Sulfur ដែលអាចធ្វើអោយមានជា AMD បាន។<br>(៤) ប្រព័ន្ធស្រះដើម្បីធ្វើទឹកអោយរង នឹងលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀង។<br>(៥) វិធីសាស្រ្តយករ៉ែធ្វើយ៉ាងណាដើម្បីបង្កលក្ខណៈងាយស្រួលដល់ការបិទរណ្តៅ<br>(៦) វិធីសាស្រ្តសម្រាប់ធ្វើការបិទរណ្តៅនិងការជួសជុលបរិស្ថានឡើងវិញ (ការកែរប្រែដី និងការដាំឈើ)។<br>(៧) វិធីសាស្រ្តដាក់ម៉្សៅផ្ទុះដែលអាចកាត់បន្ថយសម្លេងនិងរំញ័រ។ | ក្រុមហ៊ុន និងរ៉ែវិទូបរទេស និងក្រសួង | ២២០.០០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (គ) | | | | |
| ការធ្វើផែនការ | សុខភាពការងារ និងផែនការសុវត្ថភាព | • ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ ដែលក្នុងនោះត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាមួយចំនួនដូចខាងក្រោម:<br>(១) ការការពារជំងឺគ្រុនចាញ់: ក្រុមហ៊ុនត្រូវសហការជាមួយការិយាល័យសុខាភិបាលមូលដ្ឋាន និងមជ្ឈមណ្ឌលជាតិការពារជំងឺគ្រុនចាញ់ដើម្បីអនុវត្តនូវកម្មវិធីការពារជំងឺគ្រុនចាញ់។ កម្មវិធីទាំងនេះមាន: (ក) ការស្វែងរកអោយបានទាន់ពេលវេលាតាមរយៈការពិនិត្យលើលក្ខណៈគ្លីនិករបស់អ្នកផ្ទុកជំងឺដែលមានលក្ខណៈធ្ងន់ធ្ងរ (ខ) ផ្តល់ការព្យាបាលអោយបានត្រឹមត្រូវ និងគ្រប់គ្រាន់នៅគ្រប់ករណីនៃការកើតមានទាំងអស់ (គ) ធ្វើរបាយការណ៍អំពីករណីនៃការកើតមាននិងតាមដានអ្នកដែលប៉ះពាល់ឬនៅជាមួយនឹងអ្នកជំងឺ (ឃ) ផ្តល់ការណែនាំអំពីការប្រើប្រាស់ថ្នាំការពារជំងឺគ្រុនចាញ់អោយបានត្រឹមត្រូវ (ង) ជ្រលក់មុងជាមួយនឹងរបាយ Pyrathroid (ច) អនុវត្តន៍គំរោងកែលំអអនាម័យដើម្បីលុបបំបាត់កន្លែងរស់នៅរបស់មូស និងផ្តល់ការអប់រំអំពីបញ្ហាសុខភាព និងការការពារជំងឺគ្រុនចាញ់ (ឆ) ដាក់សំណាញ់តាមទ្វារនិងបង្អួចផ្ទះ (ជ) ប្រើប្រាស់មុងជាប្រចាំ (ឈ) ស្លៀកពាក់ខោអាវដៃវែង និងប្រើសារធាតុការពារមូស (ញ) តាមដានគ្លីនិកនិងរោគសញ្ញារបស់ជំងឺគ្រុនចាញ់ (ដ) ធ្វើរោគវិនិច្ឆ័យនិងផ្តល់ការព្យាបាលឱ្យបានទាន់វេលា និង (ឋ) ត្រួតពិនិត្យនូវឧប្បត្តិហេតុនិងកំណត់អំពីទីតាំងនៃការកើតមានជំងឺគ្រុនចាញ់។ | ក្រុមហ៊ុន | ១.៥០០ |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត) | | | | |
| ការធ្វើផែនការ | បទដ្ឋានសម្រាប់ការធ្វើផែនការស្រាវជ្រាវ នឹងធ្វើអាជីវកម្មរ៉ែ | (២) ការការពារជំងឺគ្រុនឈាម: ប្រសិនបើគ្មានការគ្រប់គ្រងកន្លែងដែលមូសរស់នៅអោយបានជិតដល់ទេអាចនឹងធ្វើអោយកើតជំងឺគ្រុនឈាមបាន។ អនុសាសន៍សំខាន់ៗសំរាប់ការការពារនិងការកាត់បន្ថយនូវការកើតឡើងរបស់ជំងឺមានដូចជា: (ក) សំអាតកន្លែងដែលមូសរស់នៅ (ទាំងក្នុងលក្ខខ័ណ្ឌធម្មជាតិនិងសិប្បនិម្មិត) ជាកន្លែងដែលមានទឹក បង្កលក្ខណៈសមស្របដល់ការបង្កាត់ពូជមូសដែលមាននៅជុំវិញនោះ (ខ) អប់រំកម្មករ និងសហគមន៍មូលដ្ឋាន អោយបំផ្លាញទីកន្លែងជំរករបស់មូស (គ) ធ្វើការអង្កេតនិងកំណត់អំពីដង់ស៊ីតេរបស់មូសដែលចំលងមេរោគ និង (ឃ) បាញ់ថ្នាំសំលាប់មូសជាប្រចាំ ជាពិសេសនៅពេលដែលមានមូសច្រើន។<br>(៣) វិធានការណ៍ការគ្រប់គ្រងការរាគត្បាត: វិធានការណ៍សំខាន់ៗសម្រាប់គ្រប់គ្រងការរាគត្បាតរបស់ជំងឺឆ្លងមានដូចជា: (ក) ត្រូវបំបែកអ្នកជំងឺអោយនៅកន្លែងផ្សេងនិងផ្តល់ការព្យាបាលជាពិសេសទៅតាមយថាប្រភេទនៃជំងឺ (ខ) បាញ់ថ្នាំក្នុងបរិវេណរស់នៅចំងាយ២០០មដើម្បីសម្លាប់មូសពេញវ័យ (គ) ស្វែងរកនិងបំផ្លាញទីតាំងជំរកមូស (ឃ) ចាំបាច់ត្រូវប្រើថ្នាំសំលាប់ពងមូស ចំពោះទីកន្លែងដែលមានមូសច្រើន និង (ង) អប់រំដល់បុគ្គលិកកម្មករ និងសហគមន៍អំពីវិធានការណ៍គ្រប់គ្រងការ រាគត្បាត។ | ក្រុមហ៊ុន | ១.៥០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត) | | | | |
| ការធ្វើផែនការ | បទដ្ឋានសម្រាប់ការធ្វើផែនការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ | (៤) ការការពារជំងឺដែលបង្កឡើងដោយការប្រើប្រាស់ទឹកមិនស្អាត: ការកើតជំងឺគ្រុនពោះវៀន រាគមូល អាសន្នរោគ រលាកថ្លើម និងទឹកស៊ីជើងមានកំរិតខ្ពស់ ដោយសារការខ្វះអនាម័យការប្រើប្រាស់បង្គន់សាធារណៈមានកំរិតទាប ការផ្គត់ផ្គង់ទឹកស្អាតនៅមានកំរិតនិងការខ្វះអនាម័យរបស់កម្មករ។ អនុសាសន៍មួយចំនួនដែលអនុវត្តសម្រាប់ការពារនូវការកើតនូវជំងឺខាងលើមាន: (ក) ក្រុមហ៊ុនត្រូវផ្តល់ទឹកស្អាតដល់កម្មករ។ (ខ) ត្រួតពិនិត្យជាប្រចាំ អំពីគុណភាពរបស់ទឹក (វត្តមានរបស់បាក់តេរី សារធាតុគីមី និងពណ៌របស់ទឹក) (គ) ត្រូវធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលអោយបានគ្រប់គ្រាន់និងទាន់ពេលវេលា (ឃ) តាមដានរកប្រភពចំលង និងផ្តល់ការព្យាបាល (ង) ធានាអោយបាននូវសុវត្ថិភាព និងអនាម័យកាកសំណល់ និងការបោះចោលនូវកាកសំណល់រឹងនៅក្នុងផ្ទះដែលសង់សំរាប់កម្មករ (ច) កែលំអការសម្អាតបរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ និងទីកន្លែងរស់នៅ ដោយការសង់បង្គន់អនាម័យ និងកន្លែងសំរាប់ចោលកាកសំណល់រឹង (ឆ) កែលំអរអនាម័យបុគ្គល ជាពិសេសចំពោះអ្នករៀបចំអាហារ (ជ) ផ្តល់វ៉ាក់សាំងចំពោះបុគ្គលិក ឬកម្មករបរទេសដែលពុំមានអង់ទីករប្រឆាំងជំងឺគ្រុនពោះវៀន អាសន្នរោគ និងរលាកថ្លើម និង (ឈ) រាយការណ៍នឹងធ្វើការត្រួតពិនិត្យអំពីឧប្បត្តិហេតុរបស់ជំងឺ។ | ក្រុមហ៊ុន | ៤.២០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត) | | | | |
| ការធ្វើផែនការ | បទដ្ឋានសម្រាប់ការធ្វើផែនការស្រាវជ្រាវ នឹងធ្វើអាជីវកម្មរ៉ែ | (៥) ការការពារជំងឺផ្លូវភេទ: ការការពារជំងឺផ្លូវភេទចំពោះកម្មករ និងសហគមន៍មូលដ្ឋានអាចធ្វើបានតាមរយ: (ក) អប់រំបុគ្គលិក កម្មករអំពីគ្រោះថ្នាក់នៃការឆ្លងជំងឺអេដស៍ និងជំងឺផ្លូវភេទផ្សេងៗទៀតដូចជាការទប់ស្កាត់នូវទំនាក់ទំនង ជាមួយអ្នកដែលធ្វើអាជីវកម្មលើផ្លូវភេទ ការប្រើប្រាស់ស្រោមអនាម័យ ណែនាំអ្នកជំងឺអោយព្យាបាលជាមួយនឹងគ្រូពេទ្យដែលមានបទពិសោធន៍ និងមិនត្រូវព្យាបាលដោយខ្លួនឯង និង (ខ) រាយការណ៍អំពីអ្នកជំងឺ ស្វែងរកអ្នកចំលងនិងត្រួតពិនិត្យករណីនៃការកើតមានរបស់ជំងឺ ដោយការិយាល័យសុខាភិបាលនៅក្នុងតំបន់។ ប្រសិទ្ធិភាពនៃកម្មវិធីការពារជំងឺផ្លូវភេទទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាងអាជ្ញាសុខាភិបាល អាជ្ញាធរ និងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន។ | ក្រុមហ៊ុន | ៣.០០០ |
| ការធ្វើផែនការ | បទដ្ឋានសម្រាប់ការធ្វើផែនការស្រាវជ្រាវ នឹងធ្វើអាជីវកម្មរ៉ែ | (៦) ការរៀបចំផ្ទះនិងសុខភាព: ការរៀបចំផ្ទះមិនបានត្រឹមត្រូវ (ខ្វះអនាម័យ មនុស្សច្រើនហួសកំរិត និងអាកាសអាប់អួរ) អាចនាំអោយមានការចំលងប៉ារ៉ាស៊ីត ជំងឺចំលងតាមខ្យល់ គ្រោះថ្នាក់ដោយការប៉ះទង្គិចនិងស្រ្តេសជាដើម។ តែបញ្ហាទាំងនេះអាចកាត់បន្ថយតាមរយ: ការអនុវត្តន៍នូវវិធានការណ៍មួយចំនួនដូចជា: (ក) ត្រូវរៀបចំប្លង់កសាងទីស្នាក់ស្នូល ឱ្យបានត្រឹមត្រូវ (ខ) ត្រូវផ្តល់ផ្ទះដល់កម្មករទៅតាមលក្ខខ័ណ្ឌ: (គ) ទីតាំងផ្ទះចាំបាច់ត្រូវស្ថិតនៅផុតពីកំពស់ទឹកជំនន់ ស្ថិតនៅឆ្ងាយពីទីកន្លែងដែលអាចផ្តល់ភាពក្រខ្វក់ និងកន្លែងដែលមានសត្វល្អិតច្រើន។ ផ្ទះកម្មករត្រូវមានសំណាញ់ការពារមូសនិងមានពន្លឺគ្រប់គ្រាន់។ ទីតាំងរបស់ផ្ទះនិងបន្ទប់ត្រូវមានចរន្តខ្យល់គ្រប់គ្រាន់ (ឃ) ផ្តល់ទឹកស្អាត មធ្យោបាយដុសលាង និងងូតទឹក ឱ្យបានគ្រប់គ្រាន់ សង់បង្គន់ អនាម័យ និងកន្លែងសំរាប់ចោលកាកសំណល់រឹងឱ្យត្រឹមត្រូវ និង (ង) ពិនិត្យលទ្ធភាព ក្នុងការផ្តល់កន្លែងសំរាប់លំហែ (តារាងបាល់បោះ បាល់ទះ និងបាល់ទាត់)។ | ក្រុមហ៊ុន | ៤.៥០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត) | | | | |
| ការធ្វើផែនការ | បទដ្ឋានសម្រាប់ការធ្វើផែនការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ | (៧) កំនើននៃគ្រោះថ្នាក់ក្នុងពេលធ្វើការនិងការធ្វើចរាចរៈ ដើម្បីទប់ស្កាត់នូវគ្រោះថ្នាក់ក្នុងពេលធ្វើការ និងការធ្វើចរាចរក្រុមហ៊ុនត្រូវៈ (ក) រៀបចំនិងអនុវត្តនូវគោលការណ៍សុវត្ថិភាពនិងសុខភាព (ខ) ផ្តល់មធ្យោបាយសង្គ្រោះបន្ទាន់នៅគ្រប់កន្លែងធ្វើការទាំងអស់ (គ) ផ្តល់មធ្យោបាយសំរាប់ព្យាបាលបន្ទាន់នៅក្នុងគ្លីនិករបស់ទីស្នាក់ការស្នូល (ឃ) រៀបចំវិធានការណ៍សំរាប់សង្គ្រោះបន្ទាន់ដើម្បីបញ្ជូនអ្នករងគ្រោះឬអ្នកជំងឺធ្ងន់ធ្ងរទៅកាន់មន្ទីរពេទ្យ (ង) អនុវត្តន៏ច្បាប់នៃការបើកបរនិងការណែនាំលើផ្លូវដឹកជញ្ជូនរ៉ែ និង (ច) អប់រំសហគមន៏អំពីសុវត្ថិភាពនៃការប្រើប្រាស់ផ្លូវដឹកជញ្ជូនរ៉ែ ។ | ក្រុមហ៊ុន | ៣.០០០ |
| ការរៀបចំផែនការស្រាវជ្រាវរុករករ៉ែ | បានីភ័យសុវត្ថិភាព | • ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ ការផ្តល់នូវការបណ្តុះបណ្តាលផ្សេងៗ និងការណែនាំដល់បុគ្គលិកកម្មករទាំងមុនពេលប្រគល់ភារកិច្ចផ្សេងៗ ។ | ក្រុមហ៊ុន | ៤.៥០០ |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត)** | | | | |
| ការប្រើប្រាស់ដី | ការផ្លាស់ប្តូរលំនាំនៃការប្រើប្រាស់ដី | • ផលប៉ះពាល់នេះកើតមានឡើងដោយចៀសមិនរួចឡើយ ជាពិសេសនៅក្នុងអាយុកាលនៃការធ្វើអាជីវកម្ម (ទំហំនៃការប្រើប្រាស់ដីដើម្បីធ្វើអាជីវកម្មនៅក្នុងអាយុកាលនៃការធ្វើអាជីវកម្មទៅលើរ៉ែទាំងពីរប្រភេទនេះគឺ៣.២០០ហិកតា)។ ដោយសន្និធិរបស់រ៉ែទីតានីញ៉ូមឌីអុកស៊ីដ សរុបមានចំនួនប្រមាណ ២.៤៣៥.៨០២តោន ដូច្នេះអាយុកាលនៃការធ្វើអាជីវកម្មនេះគឺ ប្រមាណ ៦៧ឆ្នាំ (មួយឆ្នាំ ៣៦០០០តោន) ដោយត្រូវឈូសឆាយដៃគំរបព្រៃប្រមាណ ៤៧ហិកតាជារៀងរាល់ឆ្នាំ។<br>• ក្រោយពេលជីកយករ៉ែអស់ហើយ ដីស្រទាប់លើនិងអាចម៍រ៉ែអាចប្រើលុបរណ្តៅរ៉ែបានប្រមាណជា៧០-៧៥ភាគរយ ពោលគឺនៅសល់ផ្ទៃរណ្តៅប្រមាណ៩៦០-៨០០ហិកតាទៀត។ ក្រុមហ៊ុនត្រូវប្រែក្លាយរណ្តៅនេះអោយក្លាយទៅជារមណីយដ្ឋានសប្បនិមិត្តមួយ ដែលមានការច្នៃប្រឌិតទៅតាមលក្ខណៈនៃសមហរីណកម្មសោភ័ណភាព បរិស្ថាន និងការសម្រាកកំសាន្ត។<br>• ប្រសិនបើពុំមានសម្ព័ន្ធគីមីសកម្មណាមួយ អាចបង្ករជាបញ្ហាសុខភាពរបស់អ្នកប្រើប្រាស់ (មនុស្ស និងសត្វ) ទេនោះ ទឹកក្នុងរណ្តៅគឺជាប្រភពប្រើប្រាស់មួយយ៉ាងសំខាន់ ក្រោយពេលបិទការដ្ឋាន។ | ម្ចាស់ក្រុមហ៊ុន | គ្មានពត៌មាន |
| ការប្រើប្រាស់ដី | ការតាំងទីលំនៅជាថ្មី | • គ្មានផលប៉ះពាល់ដែលចាំបាច់តម្រូវអោយមានការផ្លាស់ប្តូរទីតាំងជាថ្មីនោះទេ ព្រោះប្រជាពលរដ្ឋដែលរស់នៅឃុំជំនាប់ ស្រុកថ្មបាំង និងដងពែង ស្រុកស្រែអំបិលស្ថិតនៅឆ្ងាយពីទីតាំងតំបន់សម្បទានប្រមាណពី ១៦-២០គ.ម ឯណោះ។ | | |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត) | | | | |
| ការសាងសង់ទីស្នាក់ការមេ កន្លែងលាង និងកិនរ៉ែ | បង្ករការកកស្ទះដល់មជ្ឈដ្ឋានជុំវិញ និងការហូរច្រោះ ដុះដីខ្សាច់បង្ករឡើងសំណល់រុក្ខជាតិ (ឫស គុល ដើម មែក និងស្លឹក) កើតឡើងដោយការឈូសសម្អាតតំបន់ព្រៃ ចំនួន១.៥ហិកតា | • **វិធានការកាត់បន្ថយ:** ការកកស្ទះនេះអាចធ្វើការទប់ស្កាត់បានតាមរយៈការអនុវត្តន៍នូវវិធានការមួយចំនួន ដូចខាងក្រោម:<br>- ធ្វើអនាម័យដី ដោយប្រមូលកាកសំណល់ដើមឈើទាំងនោះគរទុកអោយមានសណ្តាប់ធ្នាប់។ នៅជុំវិញកន្លែងគរឈើចាំបាច់ត្រូវមានតំបន់ក្រវ៉ាត់ ដែលមានដុះរុក្ខជាតិក្រាស់ដើម្បីទប់ស្កាត់ការហូរជ័រនិងសារធាតុពុលផ្សេងៗ ទៀតចេញពីឈើ នៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង ជ័រនិងកាកសំណល់ផ្សេងៗទៀតដែលកើតមានឡើងនៅ ពេលកាប់ឈើចាំបាច់ត្រូវយកចេញ និងចោលឱ្យបានត្រឹមត្រូវ។<br>- ការធ្វើអនាម័យបែបនេះមិនត្រឹមតែអាចកាត់បន្ថយនូវផលប៉ះពាល់នេះបានទេ តែថែមទាំងអាចប្រើសំណល់ទាំងនេះអោយមានប្រយោជន៍ទៀតផង។<br>- ផ្អាកការឈូសឆាយព្រៃនៅក្នុងពេលមានភ្លៀងធ្លាក់ (ទោះតិចឬខ្លាំងក្តី)។<br>- ត្រូវរៀបចំច្បារដំណាំ ឬសួនច្បារទៅតាមប្លង់ Landscape Architecture លើផ្ទៃដីទំនេរដែលមិនប្រើប្រាស់ ដើម្បីកាត់បន្ថយការហូរច្រោះបណ្តាលពី Surface Runoff នៅពេលមានភ្លៀងធ្លាក់ខ្លាំង។ | ម្ចាស់ក្រុមហ៊ុន | ១.៥០០ |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ការជីកយករ៉ែនិងដឹកជញ្ជូនរ៉ែទៅកាន់រោងចក្រ** | | | | |
| ការឈូសសម្អាតគំរបព្រៃទំហំ ៤៧ហិកតា | បង្ករការកកស្ទះដល់មជ្ឈដ្ឋានជុំវិញ និងការហូរច្រោះ ដុះដីខ្សាច់ ដោយការឈូសសម្អាតគំរបព្រៃ ចំនួន១.៥ហិកតា | • ផលប៉ះពាល់ដែលបណ្តាលមកពីការឈូសឆាយគំរបព្រៃដើម្បីបើករណ្តៅ កើតមានឡើងដោយជាសព្វរួចឡើយ (៤៧ហិកតា/មួយឆ្នាំ)។ នៅពេលឈូសឆាយព្រៃ កាកសំណល់ដើមឈើជាច្រើន (ឫស គុល ដើម មែក និងស្លឹក) ត្រូវបាន បន្សល់ទុកដោយមិនបានសំអាតនឹងគរទុកនៅលើកំរាលព្រៃ។ ជាពិសេសរុក្ខជាតិដែលបានដុះនៅនឹង ដីគំនរសំរាមទាំងនេះ អាចនឹងបណ្តាលអោយមានផលប៉ះពាល់សំខាន់ពីរគឺ: (១) ភ្លើងឆេះ និងរាលដាលដល់ព្រៃ (ចំពោះព្រៃល្បោះ) នៅក្នុងតំបន់នោះ ជាពិសេសនៅរដូវប្រាំងពេលដែលមានអាកាសធាតុស្ងួតខ្លាំង និង (២) ធ្វើឱ្យកកស្ទះដល់ការហូររំដោះទឹក នៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង។ នេះគឺជា **ហេតុប៉ះពាល់បណ្តោះអាសន្ន (រយៈពេលខ្លី)** ហើយធ្វើការកាត់បន្ថយបានតាមវិធានការដូចខាងក្រោម :<br>- ប្រមូលកាកសំណល់គរទុកអោយមានសណ្តាប់ធ្នាប់ សម្រាប់ទុកប្រើប្រាស់ជាប្រយោជន៍ដូចជាធ្វើឧសជាដើម។<br>- ក្នុងករណីដែលប្រើក្រអស់ ហើយដើម្បីទប់ស្កាត់ភ្លើងឆេះព្រៃដោយឧបទ្ទវហេតុ ត្រូវឈូសផ្លូវភ្លើងដើម្បីទុបស្កាត់ ការឆេះរាលដាលរបស់ភ្លើង នៅពេលមានភ្លើងឆេះ។<br>- មិនត្រូវឈូសប្រមូលកាកសំណល់ឈើទាំងនេះទៅគរទុកនៅទីទំនាប ឬប្រព័ន្ធរំដោះទឹកធម្មជាតិដែលមាននៅក្នុងតំបន់នោះទេ។<br>- ផ្អាកការឈូសឆាយព្រៃនៅក្នុងពេលមានភ្លៀងធ្លាក់ (ទោះតិចឬខ្លាំងក្តី)<br>- ត្រូវលប់រណ្តៅរ៉ែ (មើលចំណុច ៨-៥ ខាងក្រោម) ជាបន្ទាន់ និងអនុវត្តការដាំឈើឡើងវិញនៅលើទីតាំងរណ្តៅនោះ ក្រោយពេលបញ្ចប់ផែនការផលិតកម្មប្រចាំឆ្នាំហើយ។ | ម្ចាស់ក្រុមហ៊ុន | ៤៧.០០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ការជីកយករ៉ែនិងដឹកជញ្ជូនរ៉ែទៅកាន់រោងចក្រ (ត)** | | | | |
| ដឹកជញ្ជូនរ៉ែទៅរោងចក្រនៅរដូវប្រាំង | ធូលីបង្កអោយប៉ះពាល់ភ្នែកនិងប្រព័ន្ធដង្ហើម និងរំខានដល់ការធ្វើរស្មីសំយោគរបស់រុក្ខជាតិ | • **វិធានការកាត់បន្ថយ:** វិធានការណ៍ផ្សេងៗ ដែលយកមកអនុវត្តសម្រាប់កាត់បន្ថយហេតុប៉ះពាល់ ទាំងនេះមានដូចជា:<br>- ប្រើម៉ាស់ និងវ៉ែនតាដើម្បីការពារភ្នែកនិងប្រព័ន្ធដកដង្ហើម<br>- ប្រើឡានដឹកទឹកផ្សើមផ្លូវជាប្រចាំ | ម្ចាស់ក្រុមហ៊ុន | - |
| សកម្មភាពធ្វើអាជីវកម្មរ៉ែ | សម្លេងធ្វើអោយមានវិបល្លាសផ្លូវចិត្ត ឬការសៅហ្មងក្នុងចិត្ត | • **វិធានការកាត់បន្ថយ:** វិធានការណ៍ផ្សេងៗ ដែលយកមកអនុវត្តសម្រាប់កាត់បន្ថយហេតុប៉ះពាល់ ទាំងនេះមានដូចជា:<br>- ប្រើបន្ទះ ឬគម្របអ្វីមួយទៅបិទបាំង (ហ៊ុំព័ទ្ធ) បរិវេណអាជីវកម្មរ៉ែ ។ ព្រោះថាការបិទបាំងនេះ អាច ជួយកាត់បន្ថយសម្លេង និងទុបស្កាត់ការបំភាយធូលី បានមួយផ្នែកផងដែរ ។<br>- បុគ្គលិកកម្មករដែលបម្រើការដោយផ្ទាល់នៅក្នុងបរិវេណអាជីវកម្មរ៉ែ ចាំបាច់ត្រូវបំពាក់នូវឧបករណ៍ការពារសម្លេង ពីព្រោះថាសម្លេងដែលបញ្ចេញពីគ្រឿងចក្រទាំងនោះអាចបង្កអោយមានបញ្ហាដល់ប្រព័ន្ធត្រចៀកបាន ។ | | - |
| ការប្រើប្រាស់ប្រេងឥន្ធនៈ | បំភាយឧស្ម័នកាបូនិក និងសារធាតុពុលបរិយាកាស | • ប្រសិនបើចាំបាច់ ត្រូវបំពាក់ឧបករណ៍ត្រងផ្សែងនៅគ្រប់គ្រឿងចក្រទាំងអស់ ដែលមាននៅក្នុងការដ្ឋានអាជីវកម្មរ៉ែនេះ ។ | | |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ការជីកយករ៉ែនិងដឹកជញ្ជូនរ៉ែទៅកាន់រោងចក្រ (ត)** | | | | |
| **យករ៉ែស្រទាប់ក្រោមដោយ ប្រើម៉ៅ្យផ្ទុះ** (Dynamite) | ផ្អើលសត្វ និងបង្កគ្រោះថ្នាក់ដល់បុគ្គលិកកម្មករធ្វើការក្នុងរណ្តៅ | • **វិធានការកាត់បន្ថយ:** វិធានការណ៍ផ្សេងៗ ដែលយកមកអនុវត្តសម្រាប់កាត់បន្ថយហេតុប៉ះពាល់ ទាំងនេះមានដូចជា:<br>- គ្មានវិធានការដាក់លាក់ណាមួយសម្រាប់អនុវត្តចំពោះសត្វព្រៃទេ។ តែជាធម្មតា សត្វព្រៃក្នុងតំបន់នឹងស៊ាំជាមួយនិងសម្លេងផ្ទុះ ចំពោះសត្វដែលផ្អើលខ្លាំង ឬជាប្រភេទសត្វដែលមានវេទនារម្មណ៍ចំពោះសម្លេងខ្លាំងបែបនេះ ក្រោយពីឮនឹងបានផ្អើលម្តងហើយក៏ធ្វើបំលាស់ទីតាមច្រករបៀងសមស្របណាមួយទៅតំបន់ផ្សេងទៀត ហើយសត្វប្រភេទនេះអាចនឹងត្រឡប់មកកន្លែងដើមវិញ ក្រោយពីបានបិទរណ្តៅរ៉ែមួយរយៈមក។<br>- អនុវត្តនីអោយបានខ្ជាប់ខ្ជួននូវបែបបទការងារ ដោយការបិទប្រកាសអំពីពេលវេលាបំផ្ទុះ និងការប្រើសីរ៉ែនដើម្បីប្រាប់អំពីពេលវេលាដែលត្រូវចុចបំផ្ទុះ។<br>- គ្មានវិធានការណ៍ជាក់លាក់ណាមួយ ដើម្បីកាត់បន្ថយជាតិអាម៉ូនីញ៉ូមនីត្រាតនៅក្នុងទឹកបានទេ តែជាធម្មតាជាតិនេះត្រូវបានបន្សាបនៅក្នុងលក្ខខ័ណ្ឌធម្មជាតិ។ | | ១២៣.៩០០ |

| | | | | |
|---|---|---|---|---|
| **ការទាញយករ៉ែ និងការរក្សាដី និងកាកសំណល់រ៉ែ** | **បាត់បង់ និងខូះសាច់ដី ដើម្បីលុបរណ្ដៅរ៉ែ** | • **វិធានការកាត់បន្ថយ:** វិធានការណ៍ផ្សេងៗ ដែលយកមកអនុវត្តសម្រាប់កាត់បន្ថយហេតុប៉ះពាល់ ទាំងនេះមានដូចជា:<br>- ត្រូវឈូសឆាយដីស្រទាប់លើយកទៅគរទុកនៅកន្លែងមួយ (ទំនាបដក់ទឹក) អោយបានត្រឹមត្រូវ ហើយដាំឬសាបគ្រាប់តិណជាតិ (ស្មៅ - ដុះលឿន នឹងជាមួយនឹងភាពរាំងឫស) ដើម្បីទប់ស្កាត់មិនអោយមានការសិកដាច់ឬហូរច្រោះ ដោយកម្លាំង តំណក់ទឹកភ្លៀង។<br>- ប្រសិនបើគ្មានកន្លែងបែបនេះទេ ក្រុមហ៊ុនត្រូវប្រើគ្រឿងចក្រ ឈូសឬកាយដីជាក្រឡុក (ប្រមាណជម្រៅ៣០-៥០ស.ម) និងមានទំហំសមស្របសម្រាប់រក្សាបរិមាណសាច់ដី។<br>- ត្រូវរក្សាអាចម៍រ៉ែទុកនៅកន្លែងផ្សេង ដើម្បីបង្កលក្ខណៈងាយស្រួលនៅពេលលុបរណ្ដៅ។ | ម្ចាស់ក្រុមហ៊ុន | ១.០០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **លាង និង/ឬទាញយករ៉ែ ចេញពីថ្ម និងការចោលកាកសំណល់** | | | | |
| **ការចោលឬទុកដាក់កាកសំណល់រ៉ែដែលមានវត្ថុមានស្ពាន់ធ័រ** | **ការហៀរចេញនូវសំណល់រាវដែលមាន** AMD (Acid Mine Drainage) | • **វិធានការកាត់បន្ថយ:** វិធានការណ៍ផ្សេងៗ ដែលយកមកអនុវត្តសម្រាប់កាត់បន្ថយហេតុប៉ះពាល់ ទាំងនេះមានដូចជា:<br>- រកទីកន្លែងសមស្រប (មានស្រទាប់ដីឥដ្ឋពីក្រោម និងមិនជ្រាបទឹក) ដើម្បីរៀបប្រព័ន្ធរក្សា និងការពារកាកសំណល់ ។<br>- ប្រព័ន្ធរក្សានិងការពារសំណល់រ៉ែចាំបាច់ត្រូវនៅដាច់ពីគេ ។ ត្រូវបញ្ចៀសទឹកដែលជ្រាបចេញពីគំនរអាចម៍រ៉ែមិនអោយហូរចូលនឹងបំពុលដល់ទឹកស្រទាប់លើ និងទឹកក្រោមដី ។ ត្រូវកាត់បន្ថយការហូររបស់ទឹកសាប (ទឹកភ្លៀងឬទឹកពីប្រភពផ្សេងៗទៀត) ទៅក្នុងប្រព័ន្ធ ។<br>- ធ្វើប្រព្រឹត្តកម្មសំណល់រាវជាមុនសិន ដើម្បីកាត់បន្ថយកំហាប់អ៊ីយ៉ុងអ៊ីដ្រូសែន ដល់កំរិតបញ្ចេញចោលមួយ(Discharge Levels) មុននឹងបញ្ចេញចោលទៅក្នុងធម្មជាតិ ។<br>- គិតគូរអំពីលទ្ធភាព និងពេលវេលារក្សាសំណល់រាវរបស់ប្រព័ន្ធ ដើម្បីធានាបានថាទឹកដែលជ្រាបចេញពីគំនរអាចម៍រ៉ែមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើអុកស៊ីតកម្មទៅលើអំបិលរ៉ែ (Thiosalt) ។ ប្រព័ន្ធរក្សានិងការពារសំណល់រ៉ែ ត្រូវមានលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀងគ្រប់គ្រាន់និងមានប្រឡាយរំដោះទឹកចេញពីប្រព័ន្ធនេះអោយបានត្រឹមត្រូវ ។<br>- ប្រព័ន្ធរក្សានិងការពារកាកសំណល់រ៉ែ ត្រូវបទដ្ឋានដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ។<br>- ប្លង់សាងសង់នេះ ត្រូវមានលក្ខណៈសមាហរណកម្មជាមួយនឹងរណ្តៅកាកសំណល់ ឬការចោលកាកសំណល់ ទោះបីជាក្រោយពេលបិទរណ្តៅរ៉ែក៏ដោយ ។ ប្រព័ន្ធរក្សានិងការពារកាកសំណល់រ៉ែនៅលើដី ចាំបាច់ត្រូវរៀបចំឡើងដើម្បីទប់ស្កាត់ភាពជ្រាបអាស៊ីដ (បណ្តាលពីការធ្វើអុកស៊ីតកម្ម) និងការជ្រាបទឹក ។ | | ៧៦.០០០ |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **លាង និង/ឬទាញយករ៉ែ ចេញពីថ្ម និងការចោលកាកសំណល់** | | | | |
| ការចោលឬទុកដាក់កាកសំណល់រ៉ែដែលមានវត្ថុមានស្ពាន់ធ័រ | ភ្លើងឆេះព្រៃបង្កឡើងដោយវត្ថុមានរបស់ Sulfide | • **វិធានការកាត់បន្ថយ:** វិធានការណ៍ផ្សេងៗ ដែលយកមកអនុវត្តសម្រាប់កាត់បន្ថយហេតុប៉ះពាល់ ទាំងនេះមានដូចជា:<br>- ឈូសព្រៃដើម្បីស្កាត់ផ្លូវភ្លើងប្រមាណ១៥-២០ម៉ែត្រ នៅជុំវិញទីតាំងគំនរអាចម៍ និងការត្រៀមសំភារ:ពន្លត់អគ្គីភ័យ ។<br>- មិនត្រូវរៀបចំទីតាំងសម្រាប់ផ្ទុកអាចម៍រ៉ែ នៅក្បែរព្រៃល្បោះ ។ | | ២.000 |
| **ការបិទរណ្តៅរ៉ែ និងការដាំឈើឡើងវិញ** | | | | |
| ការលប់ឬបិទប្រព័ន្ធធ្វើអោយទឹករង ប្រព័ន្ធរក្សានិងការពារកាកសំណល់ឬអាចម៍រ៉ែ | ដីគ្មានលទ្ធភាពអាចគាំទ្រដល់ដំណើរការជីវ: បង្កភាពក្រខ្វក់ (ពុល) ដល់មជ្ឈដ្ឋានជុំវិញ និងប្រព័ន្ធស៊ឹង ខ្វះថវិការដើម្បីជួសជុលបរិស្ថានឡើងវិញ | • **វិធានការកាត់បន្ថយ:** វិធានការណ៍ផ្សេងៗ ដែលយកមកអនុវត្តសម្រាប់កាត់បន្ថយហេតុប៉ះពាល់ ទាំងនេះមានដូចជា:<br>- ធ្វើអោយដីត្រឡប់ទៅរកស្ថានភាពមួយ ដែលមានលទ្ធភាពអាចគាំទ្រដល់ដំណើរការជីវ: មុនពេលមានការប្រើប្រាស់ដីឬក៏អាចទទួលយកបានតាមលក្ខណ:ផ្សេងទៀត ។<br>- ធ្វើយ៉ាងណាមិនឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ប្រភពទឹកនៅក្បែរៗ នោះ ។<br>- ត្រូវប្រើសំណល់ដុំថ្មលប់រណ្តៅជាមុន បន្ទាប់មកត្រូវប្រើដីស្រទាប់លើ (វត្ថុឬសម្ភារ:ផ្សេងទៀត) ដើម្បីកែប្រែដីនោះឡើងវិញទៅតាមលទ្ធភាពមួយដែលអាចទៅបាន ។<br>- ឈូសឆាយដី ឬពង្រាបដីអោយបានរាបស្មើ (កុំអោយទេរឬចោទ) ធ្វើយ៉ាងនេះដើម្បីកាត់បន្ថយការហូរច្រោះ និងការហូរនាំយកទៅនូវដីស្រទាប់លើ ។<br>- ធ្វើការដាំដុះដើមឈើឡើងវិញនូវពូជឈើក្នុងស្រុក ឬពូជឈើផ្សេងៗទៀត ដែលអាចទទួលយកបានតាមលក្ខណ:បរិស្ថាន ទប់ស្កាត់ការហូរច្រោះនិងធ្វើយ៉ាងណាដើម្បីធានាបាននូវស្ថេរភាពប្រព័ន្ធអេកូឡូស៊ីដែលមានលក្ខណ:ផលិតភាពនៅលើដីដែលកែប្រែទាំងនោះ ។ | ម្ចាស់ក្រុមហ៊ុន | ៣៩៥.000 |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ការបិទរណ្តៅរ៉ែ និងការដាំឈើឡើងវិញ (ត)** | | | | |
| ការលប់ ឬបិទប្រព័ន្ធធ្វើអោយទឹករង និង ប្រព័ន្ធរក្សាការពារសំណល់ឬអាចម៍រ៉ែ | ដីគ្មានលទ្ធភាពអាចគាំទ្រដល់ដំណើរការជីវៈ បង្ករភាពក្រខ្វក់ (ពុល) ដល់មជ្ឈដ្ឋានជុំវិញ និងប្រព័ន្ធស្ទឹង ខ្វះថវិការដើម្បីជួសជុលបរិស្ថានឡើងវិញ | - ធ្វើការគ្រប់គ្រង AMD និងកាកសំណល់ ក្រោយពេលបិទរណ្តៅរ៉ែទាំងនោះហើយ ដោយការបិទអោយជិតនូវប្រភេទកាកសំណល់ដែលសារធាតុ Pyrites ធ្វើដូច្នេះគឺដើម្បីការពារសារធាតុនេះចេញពីការធ្វើអុកស៊ីតកម្ម និងការជ្រាបនូវសារធាតុទាំងនោះចូលទៅក្នុងចរន្តទឹក។<br>- ក្រុមហ៊ុន ត្រូវមានថវិការបម្រុងគ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាពជួសជុលបរិស្ថាន។ ថវិកាបម្រុងនេះត្រូវមានចំនួនគ្រប់គ្រាន់នឹងត្រូវបម្រុងទុក , នៅក្នុងអាយុកាលនៃការធ្វើអាជីវកម្មរ៉ែទីតានីញ៉ូមឌីអុកស៊ីដ ដើម្បីប្រើប្រាស់ក្នុងការលុបរណ្តៅ នឹងកែប្រែធម្មជាតិតំបន់នោះឡើងវិញ។ | ម្ចាស់ក្រុមហ៊ុន | - |

Draft

**១៧៥.** តម្លៃដែលគ្រោងសម្រាប់ឧបត្ថម្ភ តាមដានពិនិត្យវាយតម្លៃ ពង្រឹងសមត្ថភាពប៉ាន់ស្មានថាអស់ ៥៧០.០៨០ដុល្លា (ប្រាំរយចិតសិបពាន់ប៉ែតសិបដុល្លា) ក្នុងមួយឆ្នាំក្នុងនោះមាន: (១) ការអនុវត្តន៍នូវផែនការគ្រប់គ្រងបរិស្ថាន (២) តម្រូវការអំពីការតាមដានពិនិត្យវាយតម្លៃ និង (៣) ការពង្រឹងសមត្ថភាព។ ចំពោះគំរោងថវិកាដែលគ្រោងសំរាប់ការជួសជុលនឹងកែប្រែបរិស្ថាន (លុបរណ្តៅ និងដាំព្រៃឡើងវិញ) នៅក្នុងមួយឆ្នាំៗ ត្រូវបានប៉ាន់ស្មានថាអស់ ៣៥០.០០០ដុល្លា។ ចំណែកឯថវិកាបម្រុងសម្រាប់បុគ្គលិក កម្មករ និងឬក៏ប្រជាជនសហគមន៍ ដែលទទួលគ្រោះថ្នាក់ដោយចៃដន្យ ដោយសារសកម្មភាពគំរោងនៅក្នុងរយៈពេលនៃប្រតិបត្តិការ មិនបានដាក់បញ្ចូលទៅក្នុងតារាងតម្លៃប៉ាន់ស្មានសំរាប់ ការអនុវត្តន៏ និងតាមដានពិនិត្យវាយតម្លៃនោះទេ។ តែក្រុមហ៊ុនត្រូវមានថវិកាបំរុងគ្រប់គ្រាន់សំរាប់គំរោងថវិកានេះ នៅក្នុងករណីនៃឧបទ្ទវហេតុដែលអាចកើតមានឡើងជាយថាហេតុ (មើលតារាង១០-២)។

**១៧៦.** បច្ចុប្បន្នសមត្ថភាពរបស់ម្ចាស់គំរោងក្នុងការអនុវត្តន៍នូវ EMP នៅមានកំណត់។ ដូច្នេះ ម្ចាស់គំរោងត្រូវជួលបុគ្គលិក ២នាក់ ដើម្បីត្រួតពិនិត្យតាមដានវាយតម្លៃនូវដំណើរប្រតិបត្តិការអាជីវកម្មជាប្រចាំ។ តារាង ១០-២ ខាងក្រោមនេះបង្ហាញពីតម្លៃប៉ាន់ស្មានសំរាប់ការអនុវត្តន៏នូវ EMP និងការត្រួតពិនិត្យតាមដានវាយតម្លៃនូវដំណើរប្រតិបត្តិការរបស់គំរោងស្រាវជ្រាវនឹងធ្វើអាជីវកម្មរ៉ែទីតានីញ៉ូមឌីអុកស៊ីដ។

Draft

## តារាង ១០-២: តម្លៃប៉ាន់ស្មានសម្រាប់ការអនុវត្តន៍ EMP និងការត្រួតពិនិត្យតាមដាន

| សកម្មភាព | សកម្មភាពដែលត្រូវអនុវត្ត | ចំនួន/ រយៈពេល | តំលៃជា ឯកតា ($) | តំលៃសរុប ($) |
|---|---|---|---|---|
| ការអនុវត្តន៍ វិធានការណ៍ កាត់បន្ថយ | pH Meter (អតិបរិមាប្រើបាន២ឆ្នាំ) | ២សំរាប់ | ៤៥០ | ៩០០/២ |
| | តម្លៃសម្រាប់ពិនិត្យរកលោហៈធុនធ្ងន់ COD និង BOD (២ខែម្តង) ប៉ាន់ស្មានសរុប | សរុប | ប៉ាន់ស្មានសរុប | ៧.២០០/៦ |
| | បណ្តុះបណ្តាលបុគ្គលិកពីសុខភាពការងារ និង ផែនការសុវត្ថិភាព | ៣ថ្ងៃ/៦ខែ | ៥០០ | ៣.០០០ |
| | ការរៀបចំប្រព័ន្ធធ្វើអោយទឹករង | សរុប/ការដ្ឋាន | ៤៥.០០០ | ៤៥.០០០ |
| | ការរៀបចំប្រព័ន្ធរក្សា និងការពារកាកសំណល់ | សរុប/ការដ្ឋាន | ៦៥.០០០ | ៧៥.០០០ |
| | ការធ្វើប្រព្រឹត្តកម្មទឹក (សរុប/ឆ្នាំ) | សរុប/ការដ្ឋាន | ៣.៥០០ | ៣.៥០០ |
| | ការផ្តល់ពត៌មានអំពីសុខភាពសាធារណៈ | ០ | ០ | ០ |
| ការត្រួតពិនិត្យ | ជួលបុគ្គលិកអចិន្ត្រៃយ៍ចំនួន២នាក់ដើម្បីបណ្តុះអោយធ្វើជា Local Environmental Coordinator | ០១-០២/ខែ | ១/៣៥០/ខែ | ៨.៤០០ |
| | មន្ត្រីសមត្ថកិច្ចស្រុក និងខេត្ត | ២/២ថ្ងៃ/ខែ | ១/៣០/ថ្ងៃ | ១.៤៤០ |
| | ក្រុមប្រឹក្សាឃុំ (៤នាក់) | ៤/១ថ្ងៃ/ខែ | ១/១៥/ថ្ងៃ/១២ | ៧២០ |
| | មន្ត្រីក្រសួងបរិស្ថាន (២នាក់) | ២/៣ថ្ងៃ/ខែ | ១/៣០ | ២.១៦០ |
| | មន្ត្រីក្រសួងឧស្សាហកម្ម (២នាក់) | ២/៣ថ្ងៃ/ខែ | ១/៣០ | ២.១៦០ |
| | ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ (IMO/IMB) (អ្នកជំនាញ២នាក់) | ២/៣ថ្ងៃ/២ខែ | ១/៣៥០ | ១២.៦០០ |
| ពង្រឹងសមត្ថភាព | បុគ្គលិកក្រុមហ៊ុន (អ្នកបណ្តុះបណ្តាលដែលមានជំនាញបរិស្ថានម្នាក់) | ១/៣ថ្ងៃ/៦ខែ | ៥០០/ថ្ងៃ | ៣.០០០ |
| គំរោងថវិកាសម្រាប់ជួសជុល | ការលុបរណ្តៅ (ដុល្លា/ម៉ែ$^{3}$) (ក្នុងអាយុកាលនៃការធ្វើអាជីវកម្ម) | | ១.០០/ម៉ែ$^{3}$ | ៥៥.០០០ |
| ការខូចខាតបរិស្ថាន | ការដាំឈើឡើងវិញ (ដុល្លា/ហិកតា) នៅក្នុងអាយុកាលនៃការធ្វើអាជីវកម្ម | | ១០.០០០/ហត | ៣៤០.០០០ |
| គំរោងថវិកាសំរាប់វិធានការណ៍កាត់បន្ថយ | ឧបត្ថម្ភដល់អ្នករងគ្រោះ (បុគ្គលិកកម្មករ) និងប្រជាជនក្នុងសហគមន៍ ដែលរងគ្រោះដោយឧបទ្ទវហេតុ ដោយសារសកម្មភាពរបស់គំរោង | | | តាមការជាក់ស្តែង |
| | | | | **៥៧០.០៨០** |

**១៧៧.** អ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន (Local Environmental Coordinator - LEC) នឹងត្រូវតាមដានត្រួតពិនិត្យនូវផលប៉ះពាល់ ដូចមានបង្ហាញជូនក្នុងតារាង៦-១ នៅក្នុងអាយុកាលនៃប្រតិបត្តិការអាជីវកម្មរ៉ែ ដើម្បីធានាបានថាដំណើរប្រតិបត្តិនេះបានអនុវត្តន៏ទៅតាមលក្ខខ័ណ្ឌរបស់ផែនការគ្រប់គ្រងបរិស្ថាន។ ម្ចាស់គំរោងមិនត្រូវចាប់ផ្តើមដំណើរការគំរោង មុនពេលដែលក្រសួងបរិស្ថានផ្តល់ការអនុម័តជាផ្លូវការអោយដំណើរការគំរោងនោះទេ។

**១៧៨.** ការតាមដានត្រួតពិនិត្យវាយតម្លៃគំរោង ត្រូវធ្វើទៅតាមតម្រូវការនៃការកាត់បន្ថយផលប៉ះពាល់បរិស្ថានដូចបានសង្ខេបនៅក្នុងតារាង១០-៣។ ម្ចាស់គំរោង (LEC) ត្រូវធ្វើសវនកម្មផ្ទៃក្នុងរៀងរាល់១ខែម្តងទៅលើការអនុវត្តន៏ EMP លើដំណើរការអាជីវកម្មទាំងមូល ក្នុងពេលដែលស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ (IMO/IMB) ត្រូវធ្វើសវនកម្មទៅលើការអនុវត្តន៏ EMP លើដំណើរការរបស់ប្រព័ន្ធទាំងមូល រៀងរាល់២ខែម្តង។ ការធ្វើសវនកម្មនេះចាំបាច់ត្រូវមានការចូលរួមពីមន្ត្រីរបស់ក្រសួងបរិស្ថាន ឧស្សាហកម្ម រ៉ែ និងថាមពល មន្ត្រីសមត្ថកិច្ចស្រុក និងខេត្ត ដែលអាចកំណត់អំពីកំហុសឆ្គងណាមួយ និងផ្តល់សេចក្តីកែតម្រូវតាមការចាំបាច់។ ដោយសារថាគំរោងនេះអាចនឹងនាំមកនូវផលប៉ះពាល់ពហុអវិជ្ជមាន ដូច្នេះស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ ចាំបាច់ត្រូវមានជំនាញឯកទេស២នាក់ ដែលក្រសួងបរិស្ថានជាអ្នកកំណត់ ដើម្បីចូលរួមធ្វើការត្រួតពិនិត្យ នឹងបញ្ជាក់នូវការអនុវត្តន៏ EMP ជាពិសេសដើម្បីធ្វើការផ្ទៀងផ្ទាត់ថា វិធានការណ៏កាត់បន្ថយទាំងអស់នោះត្រូវបានយកទៅអនុវត្តយ៉ាងត្រឹមត្រូវ។ ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ (IMO/IMB) មានតួនាទីទទួលខុសត្រូវក្នុងការពិនិត្យលើនីតិវិធីប្តឹងតវ៉ា ដើម្បីធានាបានថា ការផ្តល់ប្រាក់ឧបត្ថម្ភចំពោះបុគ្គលិក/កម្មករដែលរងគ្រោះ ទទួលបានការដោះស្រាយត្រឹមត្រូវពីម្ចាស់ក្រុមហ៊ុនឬមួយយ៉ាងណា ដើម្បីរាយការណ៏ទៅក្រសួងបរិស្ថាន តាមរយៈអ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន។

**១៧៩.** ម្ចាស់ក្រុមហ៊ុនត្រូវជួលជំនាញបរិស្ថាន ដើម្បីផ្តល់ការបណ្តុះបណ្តាលអំពីបទដ្ឋាននៃការគ្រប់គ្រងបរិស្ថាន គោលនយោបាយ ផែនការ និងនីតិវិធីនៃការអនុវត្តន៏ និងការត្រួតពិនិត្យតាមដានប្រព័ន្ធធ្វើប្រព្រឹត្តកម្ម ដល់បុគ្គលិករបស់ខ្លួន។ ជំនាញបរិស្ថាន ត្រូវរៀបចំសៀវភៅប្រតិបត្តិសង្ខេបដល់អ្នកសម្រប សម្រួលបរិស្ថានរបស់ក្រុមហ៊ុន។ លើសពីនេះទៀតអ្នកសំរបសំរួលបរិស្ថានត្រូវត្រួតពិនិត្យវាយតំលៃ ហើយផ្តល់នូវមតិយោបល់ផ្សេងៗដល់ម្ចាស់ក្រុមហ៊ុន ថាតើអ្នកបច្ចេកទេសបរិស្ថានរបស់ក្រុមហ៊ុន គួរមានសមត្ថភាពកំរិតណា ដើម្បីធានាបានដល់ការអនុវត្តន៏ និងការគ្រប់គ្រងការងារទាំងអស់នោះ ។

## តារាង ១០-៣: សង្ខេបអំពីតំរូវការនៃការត្រួតពិនិត្យការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មានគិតជា(ដុល្លារអាមេរិក) |
|---|---|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ - ការធ្វើផែនការ** | | | | | | |
| • ការឈូសបកដីស្រទាប់លើ ការរក្សានិងគ្រប់គ្រងអាចម៍ដីនេះអោយបានត្រឹមត្រូវសម្រាប់ ប្រើនៅពេលបិទរណ្តៅរ៉ែ។<br>• រៀបចំទីស្នាក់ការ ផ្ទះសម្រាប់បុគ្គលិកកម្មករស្នាក់នៅ រោងជាង សួនច្បារ និង ទីលានកីឡា។<br>• កំណត់ទីតាំងសម្រាប់រក្សានិងការពារកាកសំណល់រ៉ែ ជាពិសេស ប្រសិនបើកាកសំណល់ទាំងនោះមានសារធាតុ Sulfur ដែលអាចធ្វើអោយមានជា AMD បាន។<br>• ប្រព័ន្ធស្រះដើម្បីធ្វើទឹកអោយរង និងលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀង។<br>• វិធីសាស្ត្រយករ៉ែធ្វើយ៉ាងណាដើម្បីបង្កលក្ខណៈងាយស្រួលដល់ការបិទរណ្តៅ។<br>• វិធីសាស្ត្រសម្រាប់ធ្វើការបិទរណ្តៅនិងការជួសជុលបរិស្ថានឡើងវិញ (ការកែប្រែដី និងការដាំឈើ)។<br>• វិធីសាស្ត្រដាក់ម៉្សៅផ្ទុះដែលអាចកាត់បន្ថយសម្លេងនិងរំញ័រ។ | បទដ្ឋានសម្រាប់ការរៀបចំផែនការស្រាវជ្រាវ នឹងធ្វើអាជីវកម្មរ៉ែ | ការិយាល័យ | ការរៀបចំផែនការបានធ្វើទៅតាមបទដ្ឋាន នៃដំណើរការធ្វើអាជីវកម្មរ៉ែ | មុនពេលដំណើរការស្រាវជ្រាវ | ម្ចាស់គំរោង | ២២០.០០០ |

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មានគិតជា (ដុល្លាអាមេរិក) |
|---|---|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ - ការឈូសសម្អាតគំរបព្រៃ** | | | | | | |
| • ហេតុប៉ះពាល់ដែលបណ្តាលមកពីការឈូសឆាយគំរបព្រៃដើម្បីបើករណ្តៅ គឺកាកសំណល់ដើមឈើជាច្រើន (ឫស គល់ ដើម មែក និងស្លឹក) អាចបង្កអោយមានភ្លើងឆេះនិងរាលដាលដល់ព្រៃ (ព្រៃល្បោះ) និងធ្វើឱ្យកកស្ទះដល់ការហូររំដោះទឹកនៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង។ ហេតុប៉ះពាល់នេះអាចធ្វើកាត់បន្ថយបានតាមវិធានការដូចខាងក្រោម :<br>- ប្រមូលកាកសំណល់គរទុកអោយមានសណ្តាប់ធ្នាប់ សម្រាប់ទុកប្រើប្រាស់ជាប្រយោជន៍ ដូចជាធ្វើឧសជាដើម។ ក្នុងករណីដែលប្រើក្រអស់ ហើយដើម្បីទប់ស្កាត់ភ្លើងឆេះព្រៃដោយឧបទ្ទវហេតុ ត្រូវឈូសផ្លូវភ្លើងដើម្បីទុបស្កាត់ ការឆេះរាលដាលរបស់ភ្លើង នៅពេលមានភ្លើងឆេះ។<br>- មិនត្រូវឈូសប្រមូលកាកសំណល់ឈើទាំងនេះទៅគរទុកនៅទីទំនាប ឬប្រព័ន្ធរំដោះទឹកធម្មជាតិដែលមាននៅក្នុងតំបន់នោះទេ។<br>- ផ្អាកការឈូសឆាយព្រៃនៅក្នុងពេលមានភ្លៀងធ្លាក់ (ទោះតិចឬខ្លាំងក្តី)<br>- ត្រូវលប់រណ្តៅរ៉ែ (មើលចំណុច ៨-៥ ខាងក្រោម) ជាបន្ទាន់ និងអនុវត្តការដាំឈើឡើងវិញនៅលើទីតាំងរណ្តៅនោះ ក្រោយពេលបញ្ចប់ផែនការផលិតកម្មប្រចាំឆ្នាំហើយ។ | បង្ការការក្រខូកដល់មជ្ឈដ្ឋានជុំវិញដោយការឈូសសម្អាតគំរបព្រៃចំនួន៤៧ហិកតា | ទីវាល | ពិនិត្យតាមករណីនិមួយៗ | រៀងរាល់៦ខែម្តង | ម្ចាស់ក្រុមហ៊ុន ក្រសួងបរិស្ថាន ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ | ៤៧.០០០ |

Draft

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មានគិតជា (ដុល្លារអាមេរិក) |
|---|---|---|---|---|---|---|
| **ការជីកយករ៉ែនិងដឹកជញ្ជូនរ៉ែទៅកាន់កន្លែងលាង - ការជីកយករ៉ែនិងដឹកជញ្ជូនរ៉ែទៅកាន់កន្លែងលាងនៅរដូវប្រាំង** (ធូលីនិងហេតុប៉ះពាល់ចំពោះសុខភាព) | | | | | | |
| • វិធានការណ៍ផ្សេងៗ ដែលយកមកអនុវត្តសម្រាប់កាត់បន្ថយហេតុប៉ះពាល់ទាំងនេះមានដូចជា:<br>- ប្រើម៉ាស់ និងវ៉ែនតាដើម្បីការពារភ្នែកនិងប្រព័ន្ធដកដង្ហើម<br>- ប្រើហោនដឹកទឹកស្រោចផ្លូវជាប្រចាំ | ម៉ាស់និងវ៉ែនតាដែលបំពាក់អោយបុគ្គលិកកម្ម និងផ្លូវ | ទីវាល | អនុវត្តន៍បានត្រឹមត្រូវទៅតាមវិធានការណ៍នានាដែលបានកំណត់ | ២ខែម្តង | ម្ចាស់ក្រុមហ៊ុន ក្រសួងបរិស្ថាន ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ | - |
| • ប្រើបន្ទះ ឬគម្របអ្វីមួយទៅបិទបាំង (ហ៊ុំព័ទ្ធ) បរិវេណអាជីវកម្មរ៉ែ ។ ព្រោះការបិទបាំងនេះអាចជួយកាត់បន្ថយសម្លេង និងការបំភាយធូលីបានមួយផ្នែកផងដែរ ។<br>• ចាំបាច់ត្រូវបំពាក់នូវឧបករណ៍ការពារសម្លេង ព្រោះសម្លេងដែលបញ្ចេញពីគ្រឿងចក្រទាំងនោះអាចបង្ករអោយមានបញ្ហាដល់ប្រព័ន្ធត្រចៀក របស់បុគ្គលិកកម្មករដែលបម្រើការដោយផ្ទាល់នៅក្នុងបរិវេណអាជីវកម្មរ៉ែ ។ | របាំងការពារការដ្ឋាន និងឧបករណ៍ការពារត្រចៀក ដែលបំពាក់អោយបុគ្គលិកកម្ម | ទីវាល | អនុវត្តន៍បានត្រឹមត្រូវទៅតាមវិធានការណ៍នានាដែលបានកំណត់ | ៦ខែម្តង | ម្ចាស់ក្រុមហ៊ុន ក្រសួងបរិស្ថាន ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ | - |
| • ប្រសិនបើចាំបាច់ ត្រូវបំពាក់ឧបករណ៍ត្រងផ្សែងនៅគ្រប់គ្រឿងចក្រទាំងអស់ដែលមាន នៅក្នុងការដ្ឋានអាជីវកម្មរ៉ែនេះ ។ | ការបំភាយឧស្ម័នកាបូនិក..... | គ្រឿងចក្រ | អនុវត្តន៍បានត្រឹមត្រូវទៅតាមវិធានការណ៍នានាដែលបានកំណត់ | ៦ខែម្តង | ម្ចាស់ក្រុមហ៊ុន ក្រសួងបរិស្ថាន ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ | - |

Draft

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន គិតជា (ដុល្លាអាមេរិក) |
|---|---|---|---|---|---|---|
| **ការជីកយករ៉ែ និងដឹកជញ្ជូនរ៉ែទៅកាន់រោងចក្រ - ការជីករ៉ែស្រទាប់ក្រោមដោយប្រើម៉ៃ្យ** TNT | | | | | | |
| • សត្វព្រៃទាំងនោះនឹងសាំុជាមួយនឹងសម្លេងផ្ទុះ។ សត្វដែលផ្អើលខ្លាំង នឹងផ្លាស់ទីតាមច្រករបៀងណាមួយទៅរស់នៅក្នុងតំបន់ផ្សេងទៀត ហើយសត្វប្រភេទនេះអាចនឹងត្រឡប់ មកកន្លែងដើមវិញក្រោយពីបានបិទរណ្តៅរ៉ែមួយរយៈមក។<br>• អនុវត្តន៏អោយបានខ្ជាប់ខ្ជួននូវបែបបទការងារ ដោយការបិទប្រកាសអំពីពេលវេលាបំផ្ទុះនិងការប្រើសីរ៉ែន ប្រាប់អំពីពេលវេលាដែលត្រូវចុចបំផ្ទុះជាដើម។<br>• គ្មានវិធានការណ៍ជាក់លាក់ណាមួយ ដើម្បីកាត់បន្ថយជាតិអាម៉ូនីញ៉ូមនីត្រាតនៅក្នុងទឹកបានទេ តែជាធម្មតាជាតិនេះត្រូវបានបន្សាបនៅក្នុងលក្ខខ័ណ្ឌធម្មជាតិ។ | ពិនិត្យតាមករណីនិមួយ១ | ទីវាល | អនុវត្តន៏បានត្រឹមត្រូវទៅតាមវិធានការណ៏នានាដែលបានកំណត់ | រៀងរាល់៦ខែម្តង | ម្ចាស់ក្រុមហ៊ុន ក្រសួងបរិស្ថាន ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ | - |

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មានគិតជា (ដុល្លាអាមេរិក) |
|---|---|---|---|---|---|---|
| **ការទាញយករ៉ែចេញពីថ្ម និងការចោលសំណល់ (អាចម៏) រ៉ែ - ការលាងសម្អាតរ៉ែ** | | | | | | |
| • មិនត្រូវបញ្ចេញសំណល់រាវ (ទឹកលាងរ៉ែ) ចោលភ្លាមៗ ទៅក្នុងឬបង្ហូរតាមប្រភពទឹកធម្មជាតិ នៅក្នុងពេលមានភ្លៀងធ្លាក់ និងក្រោយពេលភ្លៀងធ្លាក់រួចទេ ។<br>• ប្រព័ន្ធស្រះ (ប្រព័ន្ធធ្វើអោយរង - Sedimentation Systems) ចាំបាច់ត្រូវរៀបចំឡើងតាមបទដ្ឋានបច្ចេកទេសសម្រាប់ការធ្វើអាជីវកម្មរ៉ែ ។ ប្រព័ន្ធនេះត្រូវមានលក្ខណៈក្នុងការរក្សាសំណល់រាវ អោយរងបានល្អជាមុន (ឬមានពេលវេលាគ្រប់គ្រាន់សម្រាប់ការធ្វើអុកស៊ីតកម្ម ទៅលើប្រភេទអំបិលរ៉ែ មួយចំនួនដូចជា Thiosalt ជាដើម) មុននឹងបញ្ចេញចោល ។ ការរៀបចំប្រព័ន្ធស្រះ ត្រូវផ្សារភ្ជាប់ជាមួយនឹងលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀងផងដែរ (Buffer Capacity for the Rainy Season) ព្រោះ តំបន់នោះមានរដូវប្រាំងតិចជាងបួនខែ ។ | សម្ព័ន្ធតីមីសកម្ម ធ្វើក្រខ្វក់ដល់មជ្ឈដ្ឋានជីវិញ ជាពិសេស ទឹកស្រទាប់លើ និងទឹកក្រោមដី | ទីវាល | អនុវត្តន៏បានត្រឹមត្រូវ ទៅតាមវិធានការណ៏នានា ដែលបានកំណេត់ | ១ខែ ម្តង | ម្ចាស់ក្រុមហ៊ុន ក្រសួងបរិស្ថាន ស្ថាប័ន/បុគ្គល ត្រួតពិនិត្យឯករាជ្យ | **១២៣.៥០០** |
| **ការទាញយករ៉ែ និងការរក្សាដី និងកាកសំណល់រ៉ែ** | | | | | | |
| - ត្រូវឈូសឆាយដីស្រទាប់ហើយគរទុកនៅកន្លែងមួយ (ទំនាបដក់ទឹក) អោយបានត្រឹមត្រូវ ហើយដាំឬសាបគ្រាប់តិណជាតិ (ស្មៅ - ដុះលឿន នឹងជាមួយនឹងភាពរាំងឫស) ដើម្បីទប់ស្កាត់មិនឱ្យសឹកដាច់ ឬហូរច្រោះ ដោយកម្លាំងតំណក់ទឹកភ្លៀង ។<br>- ប្រសិនបើគ្មានកន្លែងទំនាបទេ ក្រុមហ៊ុនត្រូវឈូសឬកាយដីជាក្រឡុក (ប្រមាណជម្រៅ៣០-៥០ស.ម) និងមានទំហំសមស្រប សម្រាប់រក្សាបរិមាណសាច់ដី ។<br>- ត្រូវរក្សាអាចម៏រ៉ែទុកនៅកន្លែងផ្សេង ដើម្បីងាយស្រួលនៅពេលលុបរណ្តៅ ។ | បរិមាណសាច់ដី និងសំណល់រ៉ែ ដើម្បីលុបរណ្តៅរ៉ែ | ទីវាល | អនុវត្តន៏បានត្រឹមត្រូវ ទៅតាមវិធានការណ៏នានា ដែលបានកំណត់ | បីដង (ម្តងមុនចាប់ផ្តើម ម្តងក្នុងពេលសាងសង់ និង ម្តងក្រោយពេលសង់រួច | ម្ចាស់ក្រុមហ៊ុន ក្រសួងបរិស្ថាន ស្ថាប័ន/បុគ្គល ត្រួតពិនិត្យឯករាជ្យ | **១.០០០** |

Draft

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន គិតជា (ដុល្លាអាមេរិក) |
|---|---|---|---|---|---|---|
| **ការទាញយករ៉ែ និងការចោលកាកសំណល់រ៉ែ – ការទុកដាក់សំណល់រ៉ែដែលអាចផលិត AMD** | | | | | | |
| - រកទីកន្លែងសមស្រប (មានស្រទាប់ដីឥដ្ឋពីក្រោមនិងមិនជ្រាបទឹក) ដើម្បីរៀបប្រព័ន្ធរក្សា និងការពារកាកសំណល់។ ប្រព័ន្ធនេះត្រូវនៅដាច់ពីគេ។ ត្រូវបញ្ចៀសទឹកដែលជ្រាបចេញ ពីតំនរអាចម៍រ៉ែមិនអោយហូរចូលនឹងបំពុលដល់ទឹកស្រទាប់លើនិងទឹកក្រោមដី។ ត្រូវកាត់បន្ថយការហូររបស់ទឹកសាប (ទឹកភ្លៀងឬទឹកពីប្រភពផ្សេងៗទៀត) ទៅក្នុងប្រព័ន្ធ។<br>- ធ្វើប្រព្រឹត្តកម្មសំណល់រាវជាមុនសិន ដើម្បីកាត់បន្ថយកំហាប់អ៊ីយ៉ុងរ៉ែជ្រៃសែដល់កំរិតបញ្ចេញចោលមួយមុននឹងបញ្ចោញចោលទៅក្នុងធម្មជាតិ។<br>- គិតគូរអំពីលទ្ធភាពនិងពេលវេលារក្សាសំណល់រាវរបស់ប្រព័ន្ធ ដើម្បីធានាថាទឹកដែលជ្រាបចេញពីគំនរអាចម៍រ៉ែ មានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើអុកស៊ីតកម្មទៅលើអំបិលរ៉ែ (Thiosalt)។ ប្រព័ន្ធរក្សា និងការពារសំណល់រ៉ែ ត្រូវមានលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀងនិងមានប្រឡាយរំដោះទឹកចេញពីប្រព័ន្ធឱ្យបានត្រឹមត្រូវ។<br>- ប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែ ត្រូវមានបទដ្ឋានអន្តរជាតិ។<br>- បួងសាងសង់នេះ ត្រូវមានលក្ខណៈសមាហរ័ណកម្មជាមួយនឹងរណ្តៅកាកសំណល់ឬការចោលកាកសំណល់ ទោះបីជាក្រោយពេលបិទរណ្តៅរ៉ែក៏ដោយ។ ប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែនៅលើដី ចាំបាច់ត្រូវរៀបចំឡើងដើម្បីទប់ស្កាត់ភាពជ្រាបអាស៊ីដ (បណ្តាលពីការធ្វើអុកស៊ីតកម្ម) និងការជ្រាបទឹក។ | បទដ្ឋានប្រព័ន្ធរក្សា និងការពារកាកសំណល់ និងការបំពុលដល់ទឹកស្រទាប់លើ និងទឹកក្រោមដី | ទីវាល | អនុវត្តនីបានត្រឹមត្រូវទៅតាមវិធានការណ៍នានាដែលបានកំណត់ | ១ខែ ម្តង | ម្ចាស់ក្រុមហ៊ុន ក្រសួងបរិស្ថាន ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ | ៧៦.០០០ |



Draft